ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

ថ្ងៃអង្គារ ១៤រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន (AHTN) 2022 ក្រោមកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ (AANZFTA)

យោងតាមអនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន ឆ្នាំ២០២២ ក្រោមកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ របស់រាជរដ្ឋាភិបាល និងលិខិតលេខ ៧៨៥៧ សហវ.លស.អគប. ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជន ជាពិសេសធុរជនពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបថា កម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាម AHTN 2022 ត្រូវបានដាក់ឱ្យអនុវត្តតាមអនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៣ ក្នុងរយៈពេល **៣០ថ្ងៃបន្ទាប់** ពីថ្ងៃដែលអនុក្រឹត្យនេះត្រូវបានចុះហត្ថលេខា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងធុរជនពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តប្រកបដោយប្រសិទ្ធភាព។

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

សូមស្កេន QR Code ដើម្បីទាញយកឯកសារ÷

**ព័ត៌មានលម្អិតសូមទំនាក់ទំនង÷**

- ការិយាល័យដើមកំណើតទំនិញ÷ ០១២ ៥០៥ ០៧៨
- ការិយាល័យពាណិជ្ជកម្មសេរី÷០១២ ៨១៤ ៩៥០

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ


ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៤៥៧....សហវ.ឯ.សទ៦ស


ថ្ងៃពុធ ១ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០២៣

**ជម្រាបជូន**

- **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
- **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**
- **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា**

**កម្មវត្ថុ៖** សេចក្តីជូនដំណឹង ស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន ឆ្នាំ២០២២ ក្រោមកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់។

**យោង៖** អនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន ឆ្នាំ២០២២ ក្រោមកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ** ជ្រាបថា៖ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន ឆ្នាំ២០២២ ក្រោមកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ (AANZFTA) តាមរយៈអនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៣។ ក្នុងន័យនេះ ដើម្បីឱ្យការអនុវត្តអនុក្រឹត្យខាងលើ ប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់ ខ្ញុំសូមស្នើសុំ **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ** ផ្សព្វផ្សាយអំពីការអនុវត្តនេះដល់មន្ត្រីក្រោមឱវាទពាក់ព័ន្ធ ដោយក្តីអនុគ្រោះ។ រាល់សំណួរ និងតម្រូវការព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការអនុវត្ត សូមទាក់ទងមក លោក អ៊ុយ រិទ្ធីមុនី ប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន នៃអគ្គនាយកដ្ឋានគោលនយោបាយ តាមរយៈទូរស័ព្ទលេខ ០១៧ ៩៩៣ ៣៦៨ ឬអ៊ីម៉ែល rithymonyuy@gmail.com។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ** ជ្រាប និងចាត់ចែងតាមការគួរ។

សូម **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ** ទទួលនូវការរាប់អានពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**ជូនភ្ជាប់៖**
- កម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់កម្ពុជា ក្នុង AHTN 2022 ជា Soft Copy

10-8-23


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៤៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន ឆ្នាំ២០២២ ក្រោមកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវ៉ែលហ្សេឡង់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារ នៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៤ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្តីពីការបង្កើតក្រុមប្រឹក្សាសហប្រតិបត្តិការគយ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិ ស្តីពីការធ្វើឱ្យស៊ីចង្វាក់គ្នានៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១០/០១៦ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៩ ការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ានឆ្នាំ ២០១៧ ក្រោមកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## **សម្រេច**

**មាត្រា១.~**

ដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន ឆ្នាំ២០២២ ក្រោមកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់។

កម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយនេះ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២.~**

កម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ត្រូវអនុវត្តចំពោះតែទំនិញនាំចូលទាំងឡាយណា ដែលមានដើមកំណើតនៅបណ្តាប្រទេសជាសមាជិកនៃកិច្ចព្រមព្រៀងតែប៉ុណ្ណោះ ដោយអនុលោមតាមបទប្បញ្ញត្តិនៃជំពូក ៣ ស្តីពីវិធានដើមកំណើតទំនិញ នៃកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់។

**មាត្រា៣.~**

អ្នកនាំចូលត្រូវគោរពតាមវិធាន និងនីតិវិធីនានា ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់។

**មាត្រា៤.~**

ខ្លឹមសារដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើនេះ ត្រូវចាប់ផ្តើមអនុវត្ត ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលអនុក្រឹត្យនេះ ត្រូវបានចុះហត្ថលេខា។

**មាត្រា៥.~**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៦.~**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ ចន្ទ ១ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

<u>កន្លែងទទួល</u>÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

*Unofficial Translation*

ព្រះរាជាណាចក្រកម្ពុជា

Kingdom of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

រាជរដ្ឋាភិបាល

Royal Government

No. 143 ANKr. BK

# SUB-DECREE

# ON

# The Implementation of Tariff Reduction and/or Elimination Schedule of the Kingdom of Cambodia based on the ASEAN Harmonized Tariff Nomenclature 2022 under the ASEAN – Australia – New Zealand Free Trade Agreement

## The Royal Government of Cambodia

- Having seen the constitution of the Kingdom of Cambodia;
- Having seen the Royal Decree No. NS/RKT/0918/925 dated 06 September 2018 on the Composition of the Royal Government of Cambodia;
- Having seen the Royal Decree No. NS/RKT/0320/421 dated 30 March 2020 on the amendment of the Supplement Composition of the Royal Government of Cambodia;
- Having seen the Royal Kram No. NS/RKM/0618/012 dated 28 June 2018 on the Organization and Functioning of the Council of Ministers;
- Having seen the Royal Kram No. NS/RKM/0196/18 dated 24 January 1996 on the Establishment of the Ministry of Economy and Finance;
- Having seen the Royal Kram No. NS/RKM/0297/03 dated 24 February 1997 on the Promulgation of the Law on Fiscal Tax;
- Having seen the Royal Kram No. NS/RKM/0707/017 dated 20 July 2007 on the Promulgation of the Law on Customs;
- Having seen the Royal Kram No. NS/RKM/0904/002 dated 09 September 2004 on the Promulgation of the Law on the Adoption of Protocol for the Kingdom of Cambodia to join World Trade Organization;
- Having seen the Royal Kram No. NS/RKM/0103/004 dated 20 January 2003 on the Promulgation of the Law on the Adoption for the Kingdom of Cambodia to join the Convention on the Establishment of Customs Cooperation Council;
- Having seen Royal Kram No. NS/RKM/0103/001 dated 20 January 2003 on the Promulgation of the Law on the Adoption for the Kingdom of Cambodia to join the International Convention on the Harmonized Commodity Description and Coding System;
- Having seen Royal Kram No. NS/RKM/1010/016 dated 29 October 2010 on the Promulgation of the Law on the Adoption of the Agreement establishing an ASEAN – Australia – New Zealand Free Trade Area;
- Having seen the Sub-Decree No. 488 ANKr.BK dated 16 October 2013 on the Organization and Function of the Ministry of Economy and Finance;
- Having seen the Sub-Decree No. 75 ANKr.BK dated 25 May 2017 on the amendment of Sub-decree No. 488 ONKR. BK dated 16 October 2013 on the Organization and Function of the Ministry of Economy and Finance;
- Having seen the Sub-Decree No. 32 ANKr.BK dated 8 February 2019 on the implementation of Tariff Reduction and/or Elimination Schedule of the Kingdom of Cambodia based on the ASEAN Harmonized Tariff Nomenclature 2017 under the Agreement establishing an ASEAN – Australia – New Zealand Free Trade Area;
- Referring to the need of the Ministry of Economy and Finance

**Decided**

**Article 1.-**

To promulgate the Tariff Reduction and/or Elimination Schedule of the Kingdom of Cambodia based on the ASEAN Harmonized Tariff Nomenclature (AHTN) 2022 under the Agreement establishing the ASEAN – Australia – New Zealand Free Trade Area.

The Tariff Reduction and/or Elimination Schedule are set in the Annex of this Sub-Decree.

**Article 2.-**

The Tariff Reduction and/or Elimination Schedule of the Kingdom of Cambodia as referred to the Annex of this Sub-Decree shall be applied to imported goods which are originated from the Parties of this agreement only, in accordance with the Provision of Chapter 3 (Rules of Origin) under the Agreement establishing the ASEAN – Australia – New Zealand Free Trade Area.

**Article 3.-**

Importers shall abide by rules and procedures set by the Ministry of Economy and Finance in implementing the Agreement establishing the ASEAN – Australia – New Zealand Free Trade Area.

**Article 4.-**

The Article 1 and Article 2 above shall be implemented 30 days after the date of signature of this Sub-Decree.

**Article 5.-**

Any regulations contrary to this Sub-Decree shall be invalidated.

**Article 6.-**

Minster in charge of the Council of Ministers, Minister of Economy and Finance, Ministers of all Ministries, and Heads of all Institutions shall be in charge of implementing this Sub-Decree respectively from the date of signature.

Done in Phnom Penh, 03th July 2023

**Prime Minister**

(Signature and Stamp)

**Samdech AkkaMohaSenaPadeiTecho HUN SEN**

Respectfully submitted to
Samdech AkkaMohaSenaPadeiTecho Prime Minister for Signature
**Deputy Prime Minister, Minister of Economy and Finance**

(Signature)

**AUN PORNMONIROTH**

**Copied for:**
- Ministry of Royal Palace
- General Secretariat of the Constitutional Council
- General Secretariat of the Senate
- General Secretariat of the Parliament
- Cabinet Office of Samdech AkkaMohaSenaPadeiTecho Prime Minister of Kingdom of Cambodia
- Cabinet Office of Deputy Prime Ministers
- Municipal-Provincial Hall
- As Article 6
- Royal Gazette
- Document-Archives